www.khmerpostusa.com

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies

Vol. 13. Issue #302
Oct 22Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

ក្ដៅស៊ីវ៉ាក់ត្រជាក់ស៊ីជ្រៅ

សូមអានទៅទំព័រទី ០៣



ជំនន់ទឹកភ្លៀងបណ្ដាលអោយមនុស្សចំនួន ១២នាក់

សូមអានទៅទំព័រទី ១០



សហរដ្ឋអាមេរិកាស្នើឱ្យកម្ពុជាពិនិត្យលទ្ធផល...

សូមអានទៅទំព័រទី ១១



Japan: Raise Rights on Trip to Vietnam, Indonesia Prime Minister Suga Should Use Favorable Position to Advocate Reforms



Please Read Page 12

# Cambodia Flood 2020: Death tolls up to 40 people



By Soben Pin | Facebook/Twitter@SobenPin

Cambodia — half of the country is now under water after 10 days of non-stop rain in the Southeast Asia region. The flood initially started in central Vietnam, then made its way to Thailand and Cambodia. Heavily hit provinces include Banteay Meanchey, Pursat, Battambang and Pailin – more than 50,000 homes have been impacted by the flood across the country as of Saturday October 17.

Many parts of the capitol city Phnom Penh is also flooded. Sources report Dongkor commune, Borei New World at Veng Sreng Street and many other places are affected by the flood, "people cannot enter their houses even modern or old house structures are almost full of flood so they have to move to other places for safety."

"Cambodian people, the rich are

**Continued to Page 09**

# 29th Anniversary Paris Peace Agreement Commemoration to be held (worldwide) online on October 23rd – 24th, 2020

**By Khmer Post USA**

A group of Cambodian civil society organizations have joined together to hold a commemoration of the 29th Anniversary of the 1991 Paris Peace Agreement on Friday October 23rd and Saturday 24th, 2020.

After years of conflict, 3 million loss of life, and 14 years of foreign occupation, the Paris Peace Agreement was signed in 1991, bringing the promise of peace, freedom and democracy to a broken nation.

In a statement written by the group stated, "We, Cambodians dispersed around the world remember well the hope they were filled with, when 95% of registered Cambodians voters cast their ballot for the first and only U.N. sponsored free and fair election in 1993. Within months, Prime Minister Hun Sen turned **Continued to Page 12**






មេធាវី លូយ ហាស្កែល

LAW OFFICE OF LOUIS S. HASKELL

*Excellent Service Since 1987*

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចរណ៍យន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្លូវច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence In our office to handle your legal and tax matters. We look forward to serving you well into the future.*

LAW OFFICE OF LOUIS S. HASKELL * 16 PINE STREET * LOWELL, MA * (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត មុី សុខារិទ្ធ, M.D.

**Sokharith Mey, M.D.**

លោក ចាន់ ទូច , C.N.P.

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine***

&

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហេល្ត មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

"នយោបាយកម្ពុជា"

# "ក្តៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ"

ដោយ ពិន សំខុន - ថ្ងៃទី១៩តុលា២០២០

ប៉ុន្មានខែចុងក្រោយនេះ ក្នុងអត្ថបទរបស់ខ្ញុំតែងតែកាន់យកការគាំទ្រលោក កឹម សុខា ប្រធានអតីតគណបក្សសង្គ្រោះជាតិ នៅក្នុងប្រទេសតទល់នឹងលោក សម រង្ស៊ី ដែលជាប្រធានស្តីទីនៅក្រៅប្រទេស ...តើហេតុអ្វី? តើខ្ញុំបានក្បត់វិជ្ជាជីវសារព័តិមានដែរឬទេ?

ដោយខ្ញុំចង់តែនៅជាឯករាជ្យដដែល មានន័យថា"មិនមានបំណងអ្វីផ្ទាល់ខ្លួន តែចង់បញ្ជាក់ឱ្យរតិតតែច្បាស់ពីស្មារតីរបស់ខ្ញុំ" ។វិជ្ជាជីវមិនបានកំណត់ថា "ខ្ញុំត្រូវតែឈរកណ្តាលមតិ២ដែលផ្ទុយគ្នានោះទេ" (ជាទូទៅគេឱ្យត្រូវទាំងសងខាង) ខ្ញុំបានឈរនៅខាង ១-អ្នកដែលបានធ្វើត្រូវតាមសីលធម៌ គឺមិនភូតភរមិនបង្ករគ្រោះថ្នាក់ ឬធ្វើឱ្យខាតបង់ ឬក៏អសន្តិសុខដល់អ្នកដទៃ ២-អ្នកដែលមានដំណើរនយោបាយស្របតាមទស្សនៈសេរីភាព-លទ្ធិប្រជាធិបតេយ្យដែលខ្ញុំបានឱ្យតម្លៃខ្ពស់ និង ៣-បង្ហាញឆន្ទៈនោះដោយមិនខ្លាចប្រតិកម្មអាក្រក់តបតមកវិញទេ។ ខ្ញុំបានធ្វើទៅហើយ បានផ្តល់ជាកម្លាំងនឹងការបង្ហាញផ្លូវថា "យើងមិនត្រូវខ្លាចនឹងនិយាយស្តីនូវអ្វីដែលជារឿងពិតជាមតិដែលជួយជួសជុលការញុះញង់ក្លែងក្លាយ ឬក៏កែតម្រូវការខុសឆ្គង ដែលកន្លងទៅដោយគ្មាននរណាបានឃើញ..."តែក៏មានការជេរបញ្ចោរប្រាសឆ្អេះតបមកវិញ ពីអ្នកដែលកាពារជនខិលខូចយ៉ាងឆ្អិនឆ្អៅណាស់ដែរ ។

**ក្តៅស៊ីរាក់?**

គណបក្សសង្គ្រោះជាតិ មានប្រធានស្តីទីនៃគណបក្សប្រឆាំង សម រង្ស៊ី នៅតែឡូឡាយ៉ាងខ្ទរខ្ទារថា "ហ៊ុន សែន ជានាយករដ្ឋមន្ត្រីខ្មែរ ដ៏អាក្រក់-បំប្លិចបំផ្លាញជាតិ" ប៉ុន្តែគាត់ក៏បានទទួលស្គាល់ថា "ខ្លួនជាអ្នកមានគុណរបស់គណបក្សប្រជាជន" លោក ហ៊ុន សែន ក៏បានទទួលលាភនយោបាយដ៏សំខាន់មួយពី សម រង្ស៊ី ដែលបានបន្ថយអំណាចបក្សប្រឆាំងខ្លួនឯង



ពី២ភាគ៣ មក៥០%+១ដែរ ។លោក រង្ស៊ី បន្តស្រែកថា"សម រង្ស៊ី - កឹម សុខា ជាមនុស្សតែមួយ "រីឯសកម្មភាពវិញ លោកតែងតែទៅបំបាក់បំបែកតែក្រុមគាំទ្រគណបក្សសង្គ្រោះជាតិគ្នាឯង ឯក្រៅប្រទេសនៅគ្រប់ទីកន្លែងជារៀងរាល់ថ្ងៃ ដែលលោកមិនបានខ្វល់ពីការទិទៀនអ្វីនោះទេ ។ពេលនោះ លោក រង្ស៊ី មិនបានប្រមូលកម្លាំងបក្សដូចបាវចនាដែលខ្លួនស្រែកទេ ប៉ុន្តែបែរជាបានជូនលាភសក្ការៈថ្មីមួយទៀតដល់លោក ហ៊ុន សែន គឺលោក រង្ស៊ី បានបំបែកបក្សខ្លួនឯងខ្ទេចតាមបំណង ហ៊ុន សែនទៅហើយ ។ នៅមានទង្វើច្រើនទៀត ដែលក្រុមលោក សម រង្ស៊ី បានធ្វើជា "អ្នកមានគុណរបស់គណបក្សប្រជាជន"ដូចជាលទ្ធផលនៃការបោះឆ្នោត២០១៣ ដែលលោកមិនខ្វល់ពីមតិសាធារណជនរាប់លាននាក់ ដែលចេញមកតាមផ្លូវសម្តែងការខកចិត្តពីលទ្ធផលសន្លឹកឆ្នោតដែលសង្គ្រោះជាតិអាចនឹងឈ្នះ, តែលោក រង្ស៊ី ប្រកាសឱ្យ "បាតុកររំសាយ" ទៅវិញ ឆ្នាំ២០១៤ ...នៅក្រោយមកទៀត ដូចជាស្រមៃថា "ធ្វើដំណើរទៅភ្នំពេញដើម្បីចាប់ ហ៊ុន សែន" ក៏នៅតែមានគេជឿ! ។

រួមសេចក្តីមកសម្លេងតស៊ូក្នុងបក្សប្រឆាំងរបស់ សម រង្ស៊ី បានលទ្ធផលមិនដូចបំណងប្រាថ្នានោះទេ គឺ ហ៊ុន សែន ជាអ្នកប្រកាស"លទ្ធផលឈ្នះ"ជារហូតមក។ សម្លេងពលរដ្ឋដែលក្រោកតស៊ូយ៉ាងក្តៅគគុកនៅពីក្រោយមគ្គុទេសន៏ សម រង្ស៊ី ដែលគេស្មានថា "មហាអស្ចារ្យនោះ" ពីព្រោះតែសម្តីមិនដែលញញោចឬកំសាកពេលណានោះ តែបែរជានៅរាក់កំភែលគ្មាន "គម្រោងដែលបានពិគ្រោះយោបល់" គ្មានការទទួលស្គាល់ពីសំណាក់អង្គការជាតិនឹងអន្តរជាតិ រីឯសម្លេងឆ្នោតវិញ ក៏ចេះតែខើចទៅជាលំដាប់ ទើបសម្រេចចិត្តចូលរួមចលនាសង្គ្រោះជាតិ... ដូច្នេះ,នៅសល់តែអំនួតដូច"ត្រីកំភ្លាញដែលស្លាប់ដោយសារតែមាត់"។

**ត្រជាក់ស៊ីជ្រៅ?**

នៅសល់មេបក្សសង្គ្រោះជាតិមួយទៀត ដែលខ្ញុំនៅមានសង្ឃឹមថានឹង"ប្តូរដៃពីអំណាចហ៊ុន សែន



បាន"នៅឡើយ គឺលោក កឹម សុខា ដោយសារតែភាពប្រុងប្រយ័ត្នដំណើរនៃនយោបាយត្រជាក់នៃប្រធានគណបក្សសង្គ្រោះជាតិដែលបានត្រូវរំលាយចោលរួចទៅហើយ ។ លោកមិនបានឆ្លើយតបនឹងសំនួរជាច្រើន ដែលតែងតែធ្វើឱ្យឆ្ងល់ថា"ហេតុអ្វីក៏ កឹមសុខា-សម រង្ស៊ី ជាមនុស្សតែមួយ បើនយោបាយអ្នកទាំងពីរខុសគ្នាស្រឡះ"យ៉ាងនេះ "ហេតុអ្វីក៏មិនបញ្ជាក់ពីជំហ៊ានបង្កើតគណបក្សថ្មីឬរក្សាគណបក្សសង្គ្រោះជាតិឱ្យនៅដដែល?" នៅមានសមាជិកជិតស្និតលោកមួយចំនួនបានទៅសុំសិទ្ធធ្វើនយោបាយទៅតាមច្បាប់ថ្មីនៃការបោះឆ្នោត"តើអ្នកនយោបាយទាំងនោះជាអ្នករត់ចោលជួរមែនឬទេ?"គេចាប់ខ្លួនលោក រ៉ុង ឈុន ប្រធានសហជីពកម្មករ មានគេសួរថា"តើលោក កឹម សុខា មានយោបល់យ៉ាងណា?"ស្រាប់តែគេឃើញលោកទៅលេចមុខឯពិធីបុណ្យសព ម្តាយក្មេកលោក ហ៊ុន សែន ទៅវិញ ហើយថែមទាំងធ្វើឱ្យមានការចាប់ **តទៅទំព័រទី ១៣**



# នាយឧត្តមសេនីយ៍ចាត់ដៃកង្វក់១២រូប

## ប្រវត្តិរំលោភសិទ្ធិមនុស្សដ៏យូរអង្វែងរបស់នាយឧត្តមសេនីយ៍នៃលោក ហ៊ុន សែន

ផ្តល់សិទ្ធិដោយៈ www.hrw.org/km

**តពីលេខមុន**

ឧត្តមសេនីយ៍ទោ ប៊ុន សេង អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ (ខ.ម) និងជាមេបញ្ជាការយោធភូមិភាគ ទី ៥ ឧត្តមសេនីយ៍ទោ ជឿន សុវន្នា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ (ខ.ម) និងជា មេបញ្ជាការយោធភូមិភាគ ទី ២

ឧត្តមសេនីយ៍ទោ ចាប ភក្តី នាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ (ខ.ម) និងជាមេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ (ខ.ម)

ឧត្តមសេនីយ៍ទោ រ័ត្ន ស្រ៊ាង មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជា មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ (អ.ហ)

ឧត្តមសេនីយ៍ សុខ ផល អគ្គស្នងការរងនគរបាលជាតិ និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ (ន.ប)

ឧត្តមសេនីយ៍ ម៉ក់ ជីតូ អគ្គស្នងការរងនគរបាលជាតិ និងជាអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (ន.ប) និងឧត្តមសេនីយ៍ទោ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ (ន.ប)

បុគ្គល ទាំង ១២ រូបនេះគឺជាឆ្អឹងខ្នងបង្អែកនៃរបបនយោបាយផ្តាច់ការរំលោភសិទ្ធិ មនុស្ស ដែលធ្វើឱ្យការគ្រប់គ្រងអំណាចរបស់លោក ហ៊ុន សែន រឹតតែផ្តាច់ការ។ ម្នាក់ៗនៃបុគ្គលទាំងនេះសុទ្ធតែមានទំនាក់ទំនងនយោបាយ និងទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធនឹងលោក ហ៊ុន សែន ដែលជួយធ្វើឱ្យប្រាកដថា កងទ័ពអាវុធហត្ថ និងនគរបាលបំពេញតួនាទីនយោបាយមួយធានាដល់ការគ្រប់គ្រងអំណាចរបស់គណបក្សប្រជាជនបន្តទៅទៀត។ ពួកគេម្នាក់ៗសុទ្ធតែបម្រើអាជីពការងារនៅក្នុងរដ្ឋាភិបាលដែលទទួលបានប្រាក់ខែសមគួរហើយនៅមានទ្រព្យសម្បត្តិអាថិកំបាំងដែលមិនអាចពន្យល់បានយ៉ាងច្រើនសម្បើមទៀត។



បើទោះជាម្នាក់ៗនៃបុគ្គលទាំង១២រូបនេះមានការទទួលខុសត្រូវខាងផ្លូវច្បាប់តំណាងឱ្យរដ្ឋជាជាងតំណាងឱ្យគណបក្ស ហើយត្រូវបំពេញតួនាទីរបស់ខ្លួនដោយមិនលំអៀង និងដោយអព្យាក្រឹតក្តី ក៏ប៉ុន្តែរាល់សកម្មភាពជាចំហ គឺគេធ្វើក្នុងលក្ខណៈនិយមគណបក្សខ្លាំងតែម្តង។ បុគ្គលទាំង១២រូបនេះ ជាសមាជិកគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា ដែលជាគណៈកម្មាធិការជាន់ខ្ពស់បំផុត សម្រាប់ធ្វើគោលនយោបាយគណបក្ស។សមាជិកគណៈកម្មាធិការកណ្តាលបក្សត្រូវតែអនុវត្តរាល់គោលនយោបាយរបស់គណបក្ស។ ការតម្រូវរបៀបនេះ គឺជាបញ្ហាទំនាស់ទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ តាមគោលការណ៍កងកម្លាំងប្រដាប់អាវុធមានសិទ្ធិបោះឆ្នោត និងមានសិទ្ធិបញ្ចេញមតិឯកជនរបស់ខ្លួន ប៉ុន្តែក្នុងពេលបំពេញការងារវិជ្ជាជីវរបស់ខ្លួន ពួកគេមិនអាចលម្អៀងនយោបាយទេ បើមិនដូច្នោះទេ សាធារណជននឹងមើលឃើញថា កងកម្លាំងប្រដាប់អាវុធទាំងនោះកាន់ជើងគណបក្សមួយនេះឬមួយនោះហើយ។ ការធ្វើបែបនេះ វាក៏ជាការរំលោភមាត្រា ៩ នៃច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ (ឆ្នាំ១៩៩៧) ដែរ ដែលចែងថា "យោធិនត្រូវមានអព្យាក្រឹតភាពក្នុងមុខនាទីក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ និងសម្ភារៈរបស់រដ្ឋ ដើម្បីសកម្មភាពនយោបាយណាមួយ"។

ការរំលោភបំពានដែលអ្នកទាំង១២រូបជាប់ពាក់ព័ន្ធរួមមានអំពើរំលោភសិទ្ធិមនុស្ស, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តតាំងពីទសវត្សឆ្នាំ១៩៧០ រហូតមកដល់បច្ចុប្បន្ន។ ភាគច្រើននៃអ្នកទាំង១២នាក់នេះបានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមិនចាំបាច់ជ្រុលហួសហេតុ ដែលរហូតពេលខ្លះធ្វើឱ្យស្លាប់អ្នកដែលតវ៉ាអំពីការបោះឆ្នោត ដែលមិនសេរី និងមិនត្រឹមត្រូវអំពីការរឹបអូសដីធ្លី ការរំលោភសិទ្ធិការងារ និងអំពីបញ្ហាប្រាក់ឈ្នួលតិច។ បុគ្គលទាំងនេះ ភាគច្រើន ក៏ពាក់ព័ន្ធនឹងការរំលោភបំពានដែលមិនមែនជានយោបាយដែរ ប្រឆាំងនឹងពលរដ្ឋធម្មតា ដូចជាការរឹបអូសដីធ្លីដោយរំលោភបំពានការសម្លាប់ ការធ្វើទារុណកម្ម និងការឃុំឃាំងតាមអំពើចិត្ត។ អ្នកទាំងនេះ ខ្លះបានចូលរួមនៅក្នុងរបបខ្មែរក្រហមរបស់ ប៉ុល ពត ចន្លោះពីខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩។ បុគ្គលទាំងអស់នេះ សុទ្ធតែមានតួនាទីរៀងៗខ្លួនក្នុងរយៈពេលបន្តបន្ទាប់គឺៈ ពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាពីខែមករា ឆ្នាំ១៩៧៩ ដល់ខែមេសា ឆ្នាំ១៩៨៩, សម័យរដ្ឋកម្ពុជាពីខែមេសា ឆ្នាំ១៩៨៩ ដល់ខែមិថុនា ឆ្នាំ១៩៩៣ រាប់ទាំងសម័យអ៊ុនតាក់ (UNTAC) គ្រប់គ្រងប្រទេសពីខែមីនា ឆ្នាំ ១៩៩២ ដល់ខែមិថុនា ឆ្នាំ១៩៩៣, សម័យរដ្ឋាភិបាលអន្តរកាល និងបន្តមករាជរដ្ឋាភិបាលកម្ពុជាពីខែកក្កដា ឆ្នាំ១៩៩៣ រហូតមកដល់សម័យបច្ចុប្បន្ន។

ម្នាក់ៗនៃបុគ្គលទាំង១២រូបនេះ ជាអង្គរក្សផ្ទាល់របស់លោក ហ៊ុន សែន។ អ្នកទាំង១២រូបសុទ្ធតែជំពាក់គុណបុណ្យលោក ហ៊ុន សែន ចំពោះតួនាទី មុខតំណែងជាន់ខ្ពស់ ដែលគេមានក្នុងកងកម្លាំងសន្តិសុខ។ ពួកគេមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយលោក ហ៊ុន សែន រាប់ទសវត្សមកហើយ ហើយឆន្ទៈរបស់ពួកគេ គឺការរំលោភបំពានសិទ្ធិមនុស្ស។ លោក ប៉ុល សារឿន និងគន់ គីម គឺជាសមាជិកឧបករណ៍ សន្តិសុខយោធាខ្មែរក្រហម ដូចលោក ហ៊ុន សែន ដែរ។ អ្នកទាំងបីសុទ្ធតែជាកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ា។ លោក ហ៊ុន សែន បានឆ្លងទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៧ ហើយ បានក្លាយជាបុគ្គលគន្លឹះសំខាន់មួយរូប នៅក្នុងអង្គការចាត់តាំងយោធា ដែលទំនុកបម្រុងដោយវៀតណាមក្នុងឆ្នាំ១៩៧៨។ គាត់មានតួនាទីផ្សេងទៀត នៅក្នុងរដ្ឋាភិបាលរបស់ ប៉ុល ពត ហើយក៏ជារដ្ឋមន្ត្រីការបរទេសរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជារដ្ឋមន្ត្រីក្មេងជាងលើពិភពលោក។ លោក ប៉ុល សារឿន ដែលទៅដល់ប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៨ ក៏ជាតួអង្គសំខាន់មួយដែរ ក្នុងមុខតំណែងដែលគាំទ្រដោយវៀតណាមនៅសម័យនោះ។ លោក សៅ សុខា,

**តទៅទំព័រទី០៥**



តមកពីទំព័រទី ០៤

# នាយឧត្តមសេនីយ៍បាតដៃកង្វក់១២រូប

ជា ម៉ន និង ជឿន សុវន្នា ជាជំនួយការលោក ហ៊ុន សែន ផង និងក្លាយជាសមាជិកកងកម្លាំងប្រដាប់អាវុធតូចមួយ ដែលត្រូវបានបង្កើតឡើងនៅពេលនោះដែរ។ លោក គន់ គីម, នេត សារឿន និង សុខ ផល បានក្លាយជាមនុស្សជំនិតលោក ហ៊ុន សែន យ៉ាងហោចណាស់នៅដើមទសវត្សឆ្នាំ១៩៩០ ហើយ លោក ចាប ភក្តី យ៉ាងហោចណាស់ពាក់កណ្តាលទសវត្សនោះ នៅពេលដែលអ្នកទាំងនេះដើរតួនាទីសំខាន់នៅក្នុងការធ្វើរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅឆ្នាំ១៩៩៧។ លោក ជួន សុវណ្ណ និង រ័ត្ន ស្រ៊ាង ជាកូនចៅរបស់លោក គន់ គីម ដែលជាមនុស្សមានទំនាក់ទំនងជិតស្និទ្ធ នឹងលោក ហ៊ុន សែន។

**បទរំលោភបំពាននានា នៅក្នុងសម័យខ្មែរក្រហម**

ឧត្តមសេនីយ៍ពីររូប ដែលមានកំណត់ត្រាពីការរំលោភសិទ្ធិមនុស្សយូរជាងគេ គឺលោក ប៉ុល សារឿន និង គន់ គីម។ អ្នកទាំងពីរជាសមាជិកឧបករណ៍នៃសន្តិសុខយោធាបក្សកុម្មុយនិស្តកម្ពុជារបស់ ប៉ុល ពត (ដែលគេស្គាល់ថា ខ្មែរក្រហម)។ ក្នុងពេលកំពុងកាន់អំណាចខ្មែរក្រហមជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់ពលរដ្ឋចំនួនប្រមាណពី១លាន២សែននាក់ ទៅ ២ លាន ៨ សែននាក់ ដោយសារការសម្លាប់អត់បាយ និងជំងឺ។ ចំនួននេះ គឺចន្លោះពី១៣ និង ៣០ភាគរយនៃពលរដ្ឋសរុប។ ក្នុងនោះ ក៏រាប់ចូលទាំងការស្លាប់ពាក់ព័ន្ធនឹងកាទទួលខុសត្រូវរបស់លោក ប៉ុល សារឿន និងលោក គន់ គីម នៅកន្លែងសន្តិសុខរបស់ខ្មែរក្រហម ដែលជាមណ្ឌលសួរចម្លើយធ្វើការធ្វន់ និងសម្លាប់ចោល។ លោក ប៉ុល សារឿន ជាអនុលេខានៃសេនាធិការយោធាភូមិភាគបូព៌ា ដែលគ្រប់គ្រងលើមន្ទីរសន្តិសុខតំបន់ឈ្មោះ ស-៧៩។ លោក គន់ គីម ជាប្រធានមន្ទីរសន្តិសុខស្រុកត្បូងឃ្មុំនៃតំបន់ ២១។

**អំពើរំលោភបំពាន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា**

គោលនយោបាយ និងការអនុវត្តរបស់ខ្មែរក្រហមធ្វើឱ្យខ្ទេចខ្ទាំសង្គមកម្ពុជា ហើយបង្កលក្ខណៈងាយស្រួលសម្រាប់ជ័យជម្នះនៃការឈ្លានពានរបស់វៀតណាមនៅក្នុងខែធ្នូ ឆ្នាំ ១៩៧៨ និងឈានទៅបង្កើតបានរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅក្នុងខែមករា ឆ្នាំ១៩៧៩។

រដ្ឋាភិបាលថ្មីមិនមែនដាក់បញ្ចូលតែលោក ប៉ុល សារឿន និង គន់ គីម ប៉ុណ្ណោះទេ គឺមានអតីតខ្មែរក្រហមនៅគ្រប់ជាន់ថ្នាក់ផ្សេងៗទៀត។ ក្នុងនោះ ក៏មានលោក ហ៊ុន សែន ដែលជាសមាជិកឧបករណ៍ សន្តិសុខ យោធា ខ្មែរក្រហម ម្តងម្នាក់ដែរ។ លោក ហ៊ុន សែន ធ្លាប់ជាមេបញ្ជាការយោធាខ្មែរក្រហមនៅពេលនោះ ដែលដើរតួនាទីមិនច្បាស់លាស់នៅក្នុងតំបន់ ដែលមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើង។

សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានប្រយុទ្ធប្រឆាំងដោយក្រុមខ្មែរក្រហម ដែលបានកែទម្រង់ ហើយបន្តប្រយុទ្ធតាមរបៀបទ័ពព្រៃប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាជាប់រហូតចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ ជាពេលដែល ប៉ុល ពត ស្លាប់ និងក្នុងពេលដែលចលនាខ្មែរក្រហមបែកបាក់ និងដួលរលំ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ត្រូវបានប្រយុទ្ធប្រឆាំងដោយចលនាអ្នកតស៊ូមិនមែនកុម្មុយនិស្តផ្សេងទៀតដែលគេស្គាល់ឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា ដើម្បី ឯករាជ្យ អព្យាក្រឹត សន្តិភាព និង សហប្រតិបត្តិការហៅកាត់ថា ហ៊្វុនស៊ិនប៉ិច (FUNCINPEC) ដែលត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ១៩៨១ ដោយអតីតព្រះមហាក្សត្រ សម្តេចព្រះនរោត្តម សីហនុ ហើយបន្ទាប់មករណសិរ្សនេះ ត្រូវបានដឹកនាំដោយបុត្រារបស់ព្រះ គឺព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ។

របបឯកបក្សនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើង និងពង្រឹងការគ្រប់គ្រងអំណាចរបស់ខ្លួន តាមរយៈ នយោបាយដាក់គុកទូទាំងប្រទេសដោយគ្មានការចោទប្រកាន់ ឬជំនុំជម្រះ និងតាមប្រព័ន្ធធ្វើ ទារុណកម្មអ្នកជាប់ឃុំផ្នែកនយោបាយរាប់ពាន់នាក់។ ជនជាប់ឃុំទាំងនោះ ជាច្រើននាក់បានស្លាប់ដោយសារការធ្វើបាប និងស្ថានភាពឃុំឃាំងដ៏អាក្រក់ហួសប្រមាណទាំងនោះ។

ប្រវត្តិបុគ្គល១០រូប ក្នុងចំណោម១២រូបនៅក្នុងរបាយការណ៍នេះ គឺជាប់ពាក់ព័ន្ធអំពើរំលោភទាំងនេះ តាមរយៈតួនាទីរបស់ខ្លួននៅក្នុងសេវាផ្សេងៗទាំងនៅក្នុងរបប សាធារណរដ្ឋប្រជាមានិតកម្ពុជា និងបន្តមករបបរដ្ឋកម្ពុជាដូចជាក្នុងផ្នែកនយោបាយ យោធា ផ្នែកស្រាវជ្រាវចារកិច្ច និងអង្គភាពនគរបាល ហើយផ្នែកទាំងនេះជាស្ថាប័នមូលដ្ឋាននាំអ្នកទាំងនោះ មកកាន់តួនាទីកងកម្លាំងសន្តិសុខលេចធ្លោ នៅពេលបច្ចុប្បន្ននេះ។ អំពើរំលោភបំពាននានាត្រូវបានប្រព្រឹត្តឡើងនៅក្នុងការបង្ក្រាបអ្នកងើបតវ៉ាមិនពេញចិត្តនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដោយមានវៀតណាមជាខ្នងបង្អែកផង គឺមានការឃុំឃាំងផ្នែកនយោបាយតាមអំពើចិត្ត និងការធ្វើទារុណកម្មជាប្រចាំនៅពន្ធនាគារខេត្តដែលឋិតនៅក្រោមអំណាចលោក ប៉ុល សារឿន នៅជាអភិបាលខេត្តនោះ។ ពន្ធនាគារក្រុងភ្នំពេញនៅពេលនោះ

**តទៅលេខក្រោយ**







# "កូវីត១៩" នៅចំបេះដូងនៃការបោះឆ្នោត

ដោយ ពិន សំខុន

ការបោះឆ្នោតប្រធានាធិបតីអាមេរិកាំងលើកនេះ បានត្រូវដាក់នៅក្រោមបញ្ជាការនៃ"កូវិដ១៩" យ៉ាងជាក់ច្បាស់។ លោក ឌុណល ត្រាំ ក្នុងនាមជាប្រធានាធិបតីមិនបានរុញច្រានឱ្យករណីនៃ"ជម្ងឺរាតត្បាត"មួយនេះ ឱ្យឋិតនៅក្នុងការសម្រេចចិត្តរបស់ក្រុមអ្នកឯកទេសទប់ទល់ជម្ងឺនោះទេ តែលោកបានឱបការគ្រប់គ្រងវា នៅក្នុងដៃលោកតែម្នាក់ឯង ហើយលេងសើចមើលស្រាលជាមួយនឹងជម្ងឺនេះ រហូតដល់សម្លាប់បានប្រជាពលរដ្ឋអាមេរិកាំងខ្លួនឯង តាំងពីដើមទីមកដល់ពេលនេះបានជាង២១មុឺននាក់។ នេះជាអំពើឧក្រិដ្ឋ ដែលប្រជាពលរដ្ឋជាអ្នករងគ្រោះ ហើយដែលអ្នកនយោបាយមិនហ៊ាននិយាយនៅពេលដែលបុរសខ្លាំងក្នុងប្រទេសក្តោបអំណាចគ្រប់វិស័យ។

លោក ត្រាំ មិនបានជឿថា "កូវិដ១៩"អាចសម្លាប់មនុស្សបានងាយៗនោះទេ, ហេតុនេះហើយបានជាវិធីទប់ស្កាត់យ៉ាងងាយៗ ដូចជាការ ១-ឱ្យពាក់របាំងមុខគ្រប់គ្នា ២-កុំនៅជិតគ្នាពេក ៣-ទៅធ្វើតេស្តក៏លោក ត្រាំ ឱ្យគំរូ ឬ ចេញបញ្ជាឱ្យប្រជាជាតិគោរពមិនបាន, ហើយមិនត្រឹមតែមិនជឿទេ លោក ត្រាំ ថែមទាំង"ដាក់ផុក"ទៀត ដោយមិនព្រមនៅថែខ្លួនឯងក្នុងមន្ទីរពេទ្យឱ្យបានចប់តាមវេជ្ជបញ្ជានៅពេលលោកបានឆ្លងជម្ងឺ"កូវីដ១៩", លោកសុខចិត្តចេញមកក្រៅពេទ្យ ដើម្បីចម្លងជម្ងឺដល់អ្នកឯទៀត ដូចដែលលោកបានចម្លងទៅសហការីនៃសេដ្ឋវិមាន ឬក៏ប្រជាពលរដ្ឋដែលបានមករួមប្រជុំ "រ៉ាលី"ជាមួយលោក។ ច្បាប់រដ្ឋក៏លោកមិនគោរពសម្លេងយោបល់អ្នកឯកទេស ក៏មិនស្តាប់ គឺមានតែការ"បោះឆ្នោតយកឈ្នះ"តែប៉ុណ្ណោះ ដែលមានសារសំខាន់សំរាប់លោក, ធ្វើដូច្នោះសមាជិកគណបក្សសាធារណៈរដ្ឋក៏បែកជាចំរៀកចេញពីលោកប្រធានាធិបតីនៃគណបក្សសាធារណៈរដ្ឋដែរ។







ភាពរឹងរូសរបស់លោក ត្រាំ មិនមែនតែត្រឹមលើវិស័យសុខភាព"វាយរ៉ុស"តែប៉ុណ្ណោះទេ គឺនៅវិស័យសេដ្ឋកិច្ច-សង្គមកិច្ច ដែលជាអំណួតរបស់លោកក៏ដូចគ្នាលោកប្រកាសថា លោកឈ្នះគ្រប់វិស័យ, តែអ្នកកាសែត ដែលលោកថា ជា"ព័តិមានបោកប្រាស់ Fake news "បានរកឃើញបើកក៏កាយជាសាធារណៈថា"លោកប្រធានាធិបតី ត្រាំ បានភូតភរប្រជាជាតិ" យ៉ាងឥតខ្មាស់អៀន។ សេដ្ឋកិច្ចនឹងសង្គមកិច្ចបានរង្គោះរង្គើជាខ្លាំង ពីព្រោះតែលោក ត្រាំ មិនបានទប់ស្កាត់"កូវិដ១៩"តាមវិធីសាស្ត្រសុខាភិបាលថែមទាំងប្រឆាំងនឹងបច្ចេកទេសអង្គភាពពេទ្យទាំងស្រុងផង។ បន្ទាប់ពីបានជជែកទល់មុខជាមួយបេក្ខជនប្រធានាធិបតី ជោ បាយដិន នៃគណបក្សប្រជាធិបតេយ្យមក ទើបមហាជនដឹងថា លោក ត្រាំ បាន"ចាក់ផុក" នឹងបានចាញ់បាត់ទៅហើយ(ដល់ទៅ១៥ពិន្ទុ រួមទាំងរដ្ឋមិនច្បាស់លាស់ពីមុនចំនួន៥ថែមទៀតក៏បានប្តូរដៃ) បើតាមការស្ទង់មតិផ្សព្វផ្សាយជាសាធារណៈ។ លោក ត្រាំ នៅសល់តែភ្នែកសំរាប់យំតែប៉ុណ្ណោះ គឺ "ឡាំប៉ាមិនចុះពីដំណែង" ពីព្រោះលោកនៅសល់តែ "អ្នកដើរតាម"មិនសេសសល់"អ្នកពិគ្រោះយោបល់"ទៀតទេ។

តទៅទំព័រទី០៧






តមកពីទំព័រទី ០៦

# "កូវីត១៩"នៅចំពោះមុខការបោះឆ្នោត

នៅសហភាពអឺរ៉ុបក្តីលោកប្រធានាធិបតីត្រាំ បានបាត់បង់ប្រជាប្រិយភាព បាត់បង់សម្ព័ន្ធមិត្តអស់ទៅហើយ, ការស្ទង់មតិចុងក្រោយបំផុតខែកក្កដា២០២០ នេះ នៅសហភាពអឺរ៉ុប បានបង្ហាញពីអ្នកចូលចិត្តសហរដ្ឋអាមេរិក១៥% រីឯអ្នកមិនចូលចិត្ត៦៥% ជាលោក ត្រាំ បានទទួលរង្វាន់ពី"អសមត្ថភាព" ពីការមិនប្រុងប្រយ័ត្នរបស់លោកនឹងសហការីមួយចំនួនរបស់លោករួចទៅហើយ...។ បើត្រឹមតែប្រយុទ្ធនឹង "កូវិដ១៩" ដូច្នេះវាមិនពិបាករកប្រធានាធិបតី ដែលជាអ្នកមានសមត្ថភាពគ្រាន់បើជាង ឌុណល ត្រាំ នោះ




មធ្យម- នៅអាស៊ាន ក៏លោក ត្រាំ បានបោះបង់សម្ព័ន្ធភាពចោលតាំងតែពីដើមអាណត្តិម្ល៉េះ។ គួរឱ្យសង្វេគដល់សហរដ្ឋអាមេរិក ដែលត្រូវស្តារឡើងវិញ ដោយលោកប្រធានាធិបតីថ្មីនោះណាស់, បើជាលោក ត្រាំ នៅតែដដែលទេ សហរដ្ឋនឹង"គ្មានកំណើត"បានទេ ពីព្រោះរដ្ឋបាលលោក ឌុណល ត្រាំ បានធ្វើឱ្យបាត់បង់ប្រជាប្រិយភាពនឹងកម្លាំងជាម្ចាស់ពិភពលោកអស់ទៅហើយ - លោក ត្រាំ ធ្វើនយោបាយជាបុគ្គលនិយម រីឯប្រជាជាតិធ្លាប់តែអនុវត្តន៏នយោបាយសមូហភាពប្រជាធិបតេយ្យនិយម ដែលយកប្រជាពលរដ្ឋជាសំខាន់...ប៉ុន្តែ"កូវិដ១៩"បានចែកចាយចម្លងជម្ងឺដោយមិនរើសមុខទេ ទោះជាអ្នកមានអំណាចជាប្រធានាធិបតី ឬក៏ជាប្រជាពលរដ្ឋសាមញ្ញក៏ដោយ ។ ឥឡូវទេ, ជម្រើសសមត្ថភាពគឺ ជោ បាយដិន។

ពេលនេះ ការទប់ទល់នឹង"កូវិដ១៩"គឺជាភារៈកិច្ចពលរដ្ឋទូរទៅ, ជាភារកិច្ចអ្នកឯកទេសខាងសុខភាពអាមេរីកាំង, ជាប្រព័ន្ធទាក់ទងសុខភាពប្រទេសជាតិនឹងអន្តរជាតិ, បើលោក ឌុណល ត្រាំ មិនជឿជាក់លើអ្នកឯកទេសទៅហើយ ៗទៅបង្កឱ្យជម្ងឺនេះសម្លាប់មនុស្សដោយអំណាចផ្តាច់ការនោះ, ឱកាសល្អនេះ ពលរដ្ឋម្ចាស់ឆ្នោតមានលទ្ធភាពនឹងរកបេក្ខជនដែលចេះជួយជីវិតពលរដ្ឋខ្លួន ដែលមិនមែនចេះតែចង់ឈ្នះឆ្នោតទែប៉ុណ្ណោះនោះទេ។ បេក្ខជន ជោ បាយដិន នឹង កាមេឡា ហារីស ជាជម្រើសសមរម្យបំផុតជាប្រធានាធិបតីថ្មីរបស់លោកអ្នក។






មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

## Tel: 978-459-5000

**E-mail: Tom@stylianoslaw.com**

Attorneys' only licensed in Massachusetts

Continued from page 01

# Cambodia Flood 2020: Death tolls up to 40 people

richest and the poor are poorest and no organization is taking care of mother, grandmother, grandfather who are sick in bed so how they afford, in this situation I am so worried" said Pitou Pin. Another resident at Veng Sreng Street near Pochentong International Airport posted several videos of his flooded neighborhood in Phnom Penh on Facebook and expressed "this is my city, my country, my home I don't know what's going on. The drainage clogged all the water in Phnom Penh already. Thousands of homes are in the water. All the belongings are ruined now. The water reached inside the car. Two days passed, everything is stuck" said Ricky Son.

"Last night, the bridge has fallen in Khan Dongkor, stung Preigh Thnouht, a few districts are in the water. In Kirirom, national road #4, also broke another bridge about 5 million meter cube of water pushed into Kompong Speu. In Phnom Penh, at Kandal Market the water began to go down, but my area isn't yet. The government declared a national emergency. The government and disaster management are working to rescue people and sending flood supplies" Ricky reported to Khmer Post USA on Friday night.

"The government is overwhelmed, Prime Minister Hun Sen sent out police and military officers and boats ready to rescue people, residents on Phnom Dangrek, within the Banteay Meanchey Province, a place surrounded by mountains which has never flooded before, now has flood".

Over 40 people have died and many more are under reported from the hard to reach and isolated communities where water has reached their rooftops and people have climbed up and waited to be rescued.

Princess Simarch Soth helped the ing that with so much flood, animal and humans are mixed now; we worry people will get infectious diseases. We encourage medicine donations in addition to food supplies " said Princess Simarch.

In 2011, there was also another flood but there was no resulting economic crisis. Prince Thomico Sisowath said he believes this flood is very severe that there will be a national







Veng Seng Street is also evacuated" said Ricky.

In a Khmer Post USA interview, Prince Sisowath Thomico said "Cambodia has a rainy season which often causes some parts of the country to flood but the current level of flooding is never been seen before. This is the results of global warming and secondly because of the deforestation in foods distribution in Battambang providence, reported that many people were evacuated out of their houses by the police and put plastic tents up on the side of the roads as their temporary shelters. Others seek temples, schools and family members when possible, generous neighbors also opened their home and provide victims with sleeping beds and nets. "It is also concern-

economic crisis and food shortage afterward because the flood ruined all crops in the major provinces which produce rice and livestocks. There is no clear estimate by the government of how much damage this flood has already caused.

Prime Minister Hun Sen stated that there are $6 millions contribution

**Continued To Page 15**



# ឌឹ ខេមបូឌា ដេលី The Cambodia Daily

**អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី**

## ជំនន់ទឹកភ្លៀងបណ្ដាលឱ្យមនុស្សស្លាប់១២នាក់ និងជិត១៦ម៉ឺននាក់រងការប៉ះពាល់

ឌឹ ខេមបូឌា ដេលី - October 15, 2020

ជំនន់ទឹកភ្លៀងក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ បណ្ដាលឱ្យមនុស្សយ៉ាងហោចណាស់១២នាក់ស្លាប់ និងពលរដ្ឋជិត១៦ម៉ឺននាក់ទៀត រងផលប៉ះពាល់។

របាយការណ៍ស្ដីពីការប៉ះពាល់ដោយសារគ្រោះទឹកជំនន់របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅថ្ងៃនេះឱ្យដឹងថា គិតត្រឹមថ្ងៃទី១៤ ខែតុលា ស្ថានភាពទឹកជំនន់បង្កឡើងដោយភ្លៀងធ្លាក់បណ្ដាលឱ្យមានរាជធានី-ខេត្តចំនួន១៩ រងផលប៉ះពាល់។

ក្នុងនោះមានប្រជាជនជិត៤ម៉ឺនគ្រួសារ ដែលស្មើនឹងចំនួនប្រជាជនជាង១០ម៉ឺននាក់រងផលប៉ះពាល់។ ដោយឡែកមានពលរដ្ឋចំនួន១២នាក់ បានស្លាប់ដោយសារជំនន់ទឹកភ្លៀង ហើយផ្ទះសម្បែងរបស់ពលរដ្ឋជិត៤០ម៉ឺនខ្នងរងការប៉ះពាល់។ លើសពីនេះដំណាំស្រូវនិងដំណាំផ្សេងទៀតរាប់ម៉ឺនហិកតារួមនឹងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតខូចខាតផងដែរ។ ប្រភពដដែលបន្តថា រាជធានី-ខេត្តទាំង១៩ គឺមានខេត្តនិងរាជធានីចំនួន៦ រងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ រួមមានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ខេត្តប៉ៃលិន ហើយចុងក្រោយមានរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺជាដើម។

អាជ្ញាធរខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ បានជូនដំណឹងឱ្យពលរដ្ឋខ្លួនបន្តបង្កើនការប្រុងប្រយ័ត្នត្បិតស្ថានភាពជំនន់ទឹកភ្លៀងមិនទាន់វិលទៅរកភាពប្រក្រតីនៅឡើយ។





ដោយឡែកអាជ្ញាធរខេត្តកំពង់ស្ពឺ ក៏បានជូនដំណឹងបន្ទាន់មួយថា នៅម៉ោង៤រសៀលថ្ងៃទី១៤ ខែតុលានេះ ខេត្តកំពង់ស្ពឺ នឹងមានទឹកជំនន់កើតឡើង នៅចំណុចភូមិមួយចំនួន ក្នុងស្រុកភ្នំស្រួចពិសេសនៅក្នុងក្រុងច្បារមនទាំងមូល និងមួយផ្នែកនៃស្រុកសំរោងទង។

អភិបាលខេត្តកំពង់ស្ពឺ លោក វ៉ី សំណាង អំពាវនាវលើទំព័រហ្វេសប៊ុកខ្លួនឱ្យពលរដ្ឋក្នុងភូមិសាស្ត្រពាក់ព័ន្ធទាំងអស់ ប្រញាប់រើអីវ៉ាន់ឡើងដាក់លើទីទួលសុវត្ថិភាពឱ្យបានត្រឹមត្រូវ។ ជាងនេះទៅទៀតត្រូវត្រួតពិនិត្យទៅលើចាស់ជរាកុមារដែលងាយរងផលប៉ះពាល់មុនគេ។

រីឯភូមិសាស្ត្ររាជធានីភ្នំពេញវិញ ក្រោយមានភ្លៀងធ្លាក់ខ្លាំងមួយមេកាលពីយប់ថ្ងៃទី១៣ ខែតុលា បណ្ដាលឱ្យរាជធានីភ្នំពេញស្ទើរគ្រប់តំបន់រងការលិចលង់។

នៅភូមិសាស្ត្រស្រុកកណ្ដាលស្ទឹង ប្រមុខរដ្ឋាភិបាលបានបញ្ជាឱ្យផ្អាកការធ្វើចរាចរណ៍លើកំណាត់ផ្លូវជាតិលេខ៣ ព្រោះទឹកស្ទឹងព្រែកត្នោតបានហក់ឡើងលើសពីកម្រិតប្រកាសអាសន្ន។

លើសពីនេះ ទំនប់ស្ទឹងព្រែកត្នោតកាលពីយប់មិញ គឺមិនអាចទប់ទល់ជាប់ធ្វើឱ្យពលរដ្ឋជារាប់រយគ្រួសារក្នុងសង្កាត់មួយចំនួនក្នុងខណ្ឌដង្កោរ និងនៅភូមិសាស្ត្រស្រុកកណ្ដាលស្ទឹងរងការលិចលង់ផងដែរ។

រដ្ឋបាលខេត្តកណ្ដាលនៅថ្ងៃនេះ បានចេញសេចក្ដីជូនដំណឹងមួយបញ្ជាក់ថា ដោយសារឥទ្ធិពលព្យុះជាបន្តបន្ទាប់ និងមានភ្លៀងធ្លាក់ពីមធ្យមទៅបង្គួរខេត្តកណ្ដាលបានរងឥទ្ធិពលជំនន់ទឹកភ្លៀងពីខេត្តកំពង់ស្ពឺ តាមស្ទឹងព្រែកត្នោត ដែលធ្លាក់មកដល់ទំនប់៧មករា បណ្ដាលឱ្យកម្ពស់ទឹកលើសពីកម្រិតប្រកាសអាសន្ន។

ស្ថានភាពនេះ នឹងធ្វើឱ្យប៉ះពាល់ដល់ភូមិសាស្ត្រខេត្តកណ្ដាលរួមមានស្រុកអង្គស្នួល ស្រុកកណ្ដាលស្ទឹង និងក្រុងតាខ្មៅ។ អាជ្ញាធរខេត្តនេះ ក៏បានប្រាប់ឱ្យពលរដ្ឋត្រៀមបង្ការ និងប្រុងប្រយ័ត្នខ្ពស់។

ប្រភពដដែល បានជំរុញឱ្យសមត្ថកិច្ច និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់ និងរៀបចំផែនការអន្តរាគមន៍ ដោយត្រៀមកម្លាំងទប់ស្កាត់ និងត្រៀមទីទួលសុវត្ថិភាពឱ្យបានច្បាស់លាស់ ដើម្បីជម្លៀសពលរដ្ឋរងគ្រោះ។ លើសពីនេះ ណែនាំពលរដ្ឋអំពីនាម័យ និងបង្ការជំងឺឆ្លងផ្សេងៗ។

## លោក កឹម សុខា អំពាវនាវឱ្យខ្មែរជួយគ្នាក្នុងគ្រាអាសន្ន

ឌឹ ខេមបូឌា ដេលី - October 15, 2020

ប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា បានអំពាវនាវឱ្យពលរដ្ឋខ្មែរទាំងអស់ចូលរួមជួយគ្នាក្នុងគ្រាអាសន្នតាមលទ្ធភាពរៀងៗខ្លួន។

លើកឡើងលើទំព័រហ្វេសប៊ុកនៅថ្ងៃពុធនេះ លោកកឹមសុខាឱ្យដឹងថានៅថ្ងៃទី១៤ខែតុលានេះ



លោក និងសហការីបានជួបមុខសួរសុខទុក្ខ និងបានរួមចំណែកផ្ដល់ស្បៀងអាហារដល់ពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ប្រមាណ១រយគ្រួសារដោយផ្ទាល់នៅស្រុករុក្ខគីរី ខេត្តបាត់ដំបង។ លោកបន្តថា បើទោះបីជាជំនួយរបស់លោក និងក្រុមការងារមិនច្រើនក៏ដោយប៉ុន្តែលោកនឹងព្យាយាមចូលរួមចែករំលែកបន្តទៅទៀតតាមលទ្ធភាព។

ជាមួយគ្នានេះ មេបក្សប្រឆាំងដដែលបានអំពាវនាវឱ្យពលរដ្ឋមានការប្រុងប្រយ័ត្នខ្ពស់ចំពោះគ្រោះទឹកជំនន់នៅពេលនេះ។ បន្ថែមពីនេះ លោកសូមឱ្យខ្មែរជួយគ្នាក្នុងគ្រាអាសន្ន តាមលទ្ធផលរៀងៗខ្លួន ហើយលោកក៏សូមអរគុណដល់សប្បុរសជន និងសមត្ថកិច្ច ដែលបានជួយសង្គ្រោះពលរដ្ឋក្នុងគ្រាលំបាកនេះ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា គិតត្រឹមម៉ោង៦ល្ងាចថ្ងៃពុធនេះ រដ្ឋាភិបាលបានទទួលថវិកាពីសប្បុរសជន ដែលបានចូលរួមជួយដល់ប្រជាជនរងគ្រោះដោយទឹកជំនន់ដែលកំពុងកើតឡើងនៅពេលនេះ មានចំនួនសរុបជាង ៥លាន ៥សែនដុល្លារសហរដ្ឋអាមេរិក។

ទំព័រហ្វេសប៊ុករបស់លោកបញ្ជាក់ថា ថវិកាដែលរដ្ឋាភិបាលទទួលបានពីសប្បុរសជននានានឹងចាត់ចែងជួយសង្គ្រោះបន្ទាន់ដល់ពលរដ្ឋ តាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ លោក ហ៊ុន សែន បានលើកឡើងពីពាក្យស្លោកចុងក្រោយនៃសារលើហ្វេសប៊ុករបស់លោកថា ស្រឡាញ់គ្នាក្នុងគ្រាក្រស្គាល់មិត្តល្អក្នុងគ្រាលំបាក។

ឌឹ ខេមបូឌា ដេលី The Cambodia Daily

អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

## លោក ហ៊ុន សែន ប្រាប់ឱ្យពលរដ្ឋប្រកាន់ភ្ជាប់នូវស្មារតីសាមគ្គីភាពក្នុងគ្រាជាតិជួបគ្រោះមហន្តរាយដោយធម្មជាតិ

ឌឹ ខេមបូឌា ដេលី - October 15, 2020

លោក ហ៊ុន សែន បានលើកឡើងថា ក្នុងស្ថានភាពពលរដ្ឋជួបគ្រោះមហន្តរាយពលរដ្ឋគ្រប់រូប ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវប្រកាន់ភ្ជាប់នូវស្មារតីសាមគ្គីភាព តាមរយៈវប្បធម៌ចែករំលែកផងដែរ។

ក្នុងលិខិតជូនជនរួមជាតិក្នុងឱកាសទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយក្រោមប្រធានបទការ



រស់នៅដោយសុវត្ថិភាព និងភាពធន់គ្រោះមហន្តរាយ នៅថ្ងៃទី១៣ ខែតុលាឆ្នាំ២០២០នេះ លោក ហ៊ុន សែន បានលើកឡើងថា គ្រោះមហន្តរាយដែលបង្កដោយគ្រោះថ្នាក់ធម្មជាតិមានជាច្រើន។

ជាក់ស្តែងបញ្ហាទឹកជំនន់ភាពរាំងស្ងួត ខ្យល់កន្ទ្រាក់ និងជំងឺរាតត្បាត ជាដើម វាបានកើតឡើងជារៀងរាល់ឆ្នាំ ធ្វើឱ្យខាតបង់ថវិកាជាតិប៉ះពាល់លើសេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងប៉ះពាល់ដល់អាជីវិតទៀតផង។

ក្នុងលិខិតនោះ លោក ហ៊ុន សែន បានដាក់ចេញវិធានការ៦ចំណុចសំដៅដល់ការបង្កើនប្រសិទ្ធភាពជួយសង្គ្រោះអ្នករងគ្រោះដោយទឹកជំនន់។

វិធានការទាំងនោះ លោកក៏បានជំរុញឱ្យអាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវបន្តអនុវត្ត និងប្រកាន់ភ្ជាប់នូវជារៀងរហូតនូវស្មារតីសាមគ្គីភាព តាមរយៈវប្បធម៌ចែករំលែកជួយគ្នាទៅវិញទៅមក និងប្រពៃណីចូលរួមសហការឱ្យបានកាន់តែរឹងមាំថែមទៀត ក្នុងការរក្សាស្ថិរភាពសង្គម។

លើសពីនេះ ត្រូវចូលរួមកែលម្អ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ងាយរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ ព្រមទាំងត្រូវយកចិត្តទុកដាក់លើសមត្ថភាព និងលទ្ធភាពផ្ទាល់ខ្លួន ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយឱ្យទាន់ពេលវេលា។

ជាងនេះទៀត ត្រូវបន្តចែករំលែកចំណេះដឹងដើម្បីសុខភាពសាធារណៈបង្កើនប្រសិទ្ធភាពជួយសង្គ្រោះ ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ រួមទាំងវិស័យឯកជនរួមគ្នាដោះស្រាយរៀបចំគម្រោងសុវត្ថិភាពនៅមូលដ្ឋានដែលងាយរងគ្រោះ និងចូលរួមផ្សព្វផ្សាយការយល់ដឹងដើម្បីកាត់បន្ថយហានិភ័យដែលកើតឡើងពីគ្រោះធម្មជាតិទាំងឡាយ។

របាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយកាលពីថ្ងៃម្សិលមិញបានឱ្យដឹងថា គ្រោះធម្មជាតិដែលបង្កឡើងដោយជំនន់ទឹកភ្លៀងនាប៉ុន្មានថ្ងៃមកនេះ បណ្តាលឱ្យមនុស្ស១០នាក់បាត់បង់ជីវិត និងមនុស្សជិតមួយម៉ឺននាក់ត្រូវជម្លៀសទៅទីទួលសុវត្ថិភាព។

ខេត្តដែលរងគ្រោះធ្ងន់ធ្ងរជាងគេរួមមានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន ផងដែរ។

សេចក្តីជូនដំណឹងរបស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី១៣ ខែតុលានេះ ស្តីពីស្ថានភាពអាកាសធាតុចន្លោះពីថ្ងៃទី១៤ ដល់ថ្ងៃទី២០ ខែតុលា បានឱ្យដឹងថា ព្យុះទី១៦ ឈ្មោះ ណាងកា (Nangka) និងព្យុះទី១៧ ឈ្មោះ សូដែល (Saudel) ដែលមានកម្លាំងខ្លាំង នឹងមានឥទ្ធិពលលើផ្នែកខ្លះនៃប្រទេសវៀតណាម។ បាតុភូព្យុះទាំងនេះ នឹងបន្ថយឥទ្ធិពលជាបន្តបន្ទាប់ ដោយបន្តឆ្លងកាត់ចូលប្រទេសកម្ពុជាតាមខេត្តរតនគិរី ចាប់ពីថ្ងៃទី១៨ និង១៩ ខែតុលា ក្នុងកម្លាំងជាវិសម្ពាធ និងសម្ពាធទាប។

ក្រសួងបន្តថា ប្រព័ន្ធសម្ពាធទាបនេះនឹងបន្តលាតសន្ធឹងលើប្រទេសកម្ពុជា ដែលនាំឱ្យមានភ្លៀងធ្លាក់លាយឡំខ្យល់បក់ខ្លាំងនិងរលកសមុទ្រខ្ពស់ៗ ចាប់ពីថ្ងៃទី១៦-២០ ខែតុលា ឆ្នាំ២០២០។

អាស្រ័យដូចបានជម្រាបជូននេះ ក្រសួងធនធានទឹក បានអំពាវនាវដល់ប្រជាពលរដ្ឋដែលរស់នៅទីទំនាប ក្បែរផ្លូវទឹក ជាប់តំបន់ភ្នំ និងជួរភ្នំ ត្រូវមានការប្រុងប្រយ័ត្នចំពោះជំនន់ទឹកភ្លៀង បាតុភូតផ្គរ រន្ទះ ខ្យល់កន្ទ្រាក់ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០។

## សហរដ្ឋអាមេរិកស្នើឱ្យកម្ពុជាពិនិត្យលទ្ធផលបន្តដំណើរការ ទទួលពលរដ្ឋខ្មែរដែលត្រូវបញ្ជូនពីអាមេរិកឡើងវិញ

ឌឹ ខេមបូឌា ដេលី - October 10, 2020

សហរដ្ឋអាមេរិក តាមរយៈឯកអគ្គរដ្ឋទូតរបស់ខ្លួនប្រចាំកម្ពុជា បានស្នើរដ្ឋាភិបាលខ្មែរឱ្យពិនិត្យលទ្ធភាពដើម្បីបន្តដំណើរការទទួលពលរដ្ឋអាមេរិកាំងដែលមានដើមកំណើតខ្មែរ ដែលនឹងត្រូវបណ្តេញចេញពីប្រទេសលោកសេរីមួយនេះឡើងវិញ។

ការស្នើនេះក្នុងជំនួបរវាងឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក Patrick Murphy កាលពីថ្ងៃពុធម្សិលមិញ។

ទំព័រហ្វេសប៊ុករបស់លោក ស ខេង ដែលបង្ហោះការពីយប់ថ្ងៃពុធថា ក្នុងជំនួបរវាងមន្ត្រីជាន់ខ្ពស់នោះ ភាគីទាំងពីរបានជជែកគ្នាច្រើនអំពីទំនាក់



ទំនងល្អរវាងកម្ពុជា-អាមេរិកនិងកិច្ចពិភាក្សាការងារធំៗជាច្រើនទៀត ព្រមទាំងការប្តេជ្ញាកសាងទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យកាន់តែប្រសើរ។

ក្នុងចំណោមកិច្ចពិភាក្សាលើការងារធំៗ ទាំងនោះ លោក ស ខេង បញ្ជាក់ថា លោក Patrick Murphy បានលើកឡើងពីកិច្ចការសំខាន់មួយ គឺពាក់ព័ន្ធនឹងការងារមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរនៅសហរដ្ឋអាមេរិកមកកាន់កម្ពុជា ក្រោយពេលការងារនេះ ត្រូវបានផ្អាកមួយរយៈពេលដោយសារវិបត្តិជំងឺកូវីដ១៩។

ប្រភពដដែលបន្តថា ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា បានស្នើឱ្យភាគគី កម្ពុជា និងស្នើទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្ទាល់ ដើម្បីពិនិត្យលទ្ធភាពរិះរកវិធីសាស្ត្រក្នុងការបន្តជំរុញអនុវត្តការងារនេះឱ្យមានដំណើរការឡើងវិញ។

ជាការឆ្លើយតបលោក ស ខេង ក៏បានប្រាប់ទៅលោក Patrick Murphy វិញថា ជាគោលការណ៍និងឆន្ទៈនយោបាយគឺកម្ពុជាមិនមានអ្វីប្រែប្រួលនោះទេ គឺនៅតែបន្តអនុវត្តនូវអ្វីដែលរដ្ឋាភិបាលប្រទេសទាំងពីរបានឯកភាព និងព្រមព្រៀងគ្នាកាលពីពេលកន្លងទៅ។ លើសពីនេះ លោកអះអាងថា ទោះបីមានការខកខានដោយសារជំងឺកូវីដ១៩ក្តី ប៉ុន្តែគោលការណ៍ និងឆន្ទៈនយោបាយមិនមានអ្វីប្រែប្រួលនោះឡើយ។

ការលើកឡើងពីបញ្ហាពលរដ្ឋខ្មែរ ដែលត្រូវបញ្ជូនមកកម្ពុជាវិញ ទាំងក្នុងស្ថានភាពនៃវិបត្តិកូវីដ១៩នេះ ស្របពេលមានសេចក្តីរាយការណ៍ពីការវាយកម្ទេចអាគារមួយដែលជាជំនួយសហរដ្ឋ-អាមេរិកនៅមូលដ្ឋានយោធារាមក្នុងខេត្តព្រះសីហនុ។ លើសពីនេះ បញ្ហាទំនាក់ទំនងកម្ពុជា-អាមេរិកនៅមិនទាន់មានភាពល្អប្រសើរនៅឡើយទេ។

កាលពីឆ្នាំ២០០២ រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាមេរិក បានចុះកិច្ចព្រមព្រៀងមួយដោយសម្រេចបញ្ជូននិងទទួលយកពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងបញ្ជូនពលរដ្ឋខ្មែរណា ដែលប្រព្រឹត្តបទឧក្រិដ្ឋឱ្យត្រឡប់មកមាតុភូមិវិញ ក្រោយពេលអនុវត្តទោសរួចរាល់។

បើតាមអង្គការសេរ៉ាក់ (SEARAC) បានឱ្យដឹងថាគិតត្រឹមខែធ្នូ ឆ្នាំ២០១៨ មានពលរដ្ឋខ្មែរជិត៩០០នាក់ហើយ ត្រូវបានបញ្ជូនចេញពីសហរដ្ឋអាមេរិក ចាប់តាំងពីប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយនឹងសហរដ្ឋអាមេរិកកាលពីឆ្នាំ២០០២មក។

ដោយឡែកតាមរបាយការណ៍របស់នាយកដ្ឋានអន្តោប្រវេសអាមេរិក កាលពីខែកញ្ញា ឆ្នាំ២០១៨ ឱ្យដឹងថា មានពលរដ្ឋខ្មែរជិត២ពាន់នាក់ (១៨៥៥) ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរអាមេរិក ហើយក្នុងនោះមានពលរដ្ឋចំនួន ១៣៦២ នាក់រកឃើញថា បានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌប្រឈមនឹងការបញ្ជូនមកកម្ពុជាវិញ។

# Japan: Raise Rights on Trip to Vietnam, Indonesia Prime Minister Suga Should Use Favorable Position to Advocate Reforms

By Khmer Post USA

Human Rights Watch, in an October 16 letter, urged newly elected Japan Prime Minister Yoshihide Suga to address the concerns about Vietnam's widespread violations of civil and political rights, including freedom of expression, peaceful assembly, and movement. He was also urged to criticize Indonesia's suppression on freedom of religion, press freedom, the rights to sexual orientation and gender identity, and the rights of Indigenous peoples. Prime Minister Yoshihide Suga scheduled his first foreign trip to Indonesia and Vietnam from October 18 – 21, 2020.

"Japan should use its significant leverage as a major donor to the Vietnamese and Indonesian governments to press both to stop violating human rights," said Phil Robertson, deputy Asia director. "Prime Minister Suga should publicly and privately show that Japan is serious about its policy declarations to promote human rights abroad."


Japan Prime Minister Yoshihide Suga

People who criticize the Vietnamese government or the ruling Communist Party are subjected to police harassment, restricted movement, physical assault, arbitrary arrest and detention, and imprisonment. The police routinely detain political activists for months without access to legal counsel and subject them to bullying interrogation. Vietnamese authorities have also shut down access to politically independent websites and social media pages, while pressuring social media and telecommunication companies to remove content deemed critical of the government or the party.

Read full statement here on Human Rights Watch website at: https://www.hrw.org/news/2020/10/18/japan-raise-rights-trip-vietnam-indonesia

Continued from Front page

## 29th Anniversary Paris Peace Agreement Commemoration to be held (worldwide) online on October 23rd – 24th, 2020

that promise into a still on-going one party rule for the past three decades. Cambodians overseas hold these commemorations every year to remind the world and the Cambodian government of the broken promises of freedom, democracy and territorial integrity guaranteed by those Agreements."

The group said they will strive for the peaceful implementation of all the provisions of the 1991 Paris Peace Agreements and to hold the government of Cambodia accountable for any violations of its provisions, until those promises are fulfilled.

The recent arrests of youth activists and union leader Mr. Rong Chun, the unlawful arrest of opposition party leader Mr. Kem Sokha and the dissolution of the opposition party CNRP (which had 53 parliamentary members in 2017), and the 2018 one-party election of Prime Minister Hun Sen shows the current broken system in Cambodia and a clear violation of the 1991 Paris Peace Agreement.

The 29th Annual Paris Peace Agreement virtual event will kick-off on Friday October 23rd from 10 am – 1:30 pm, notable speakers will include Australian legislator Federal MP Julian Hill, Brad Adams Human Rights Watch Asia Director, International Lawyer Morton Sklar, Professor Stephen Morris, author of "Why Vietnam Invaded Cambodia", U.S. officials, international and Cambodian human rights organizations. On Saturday October 24th, the program will be held in Khmer language from 10 am – 8 pm Eastern time. Topics will include PPA violations and PPA+ solutions.

The public is invited to join the virtual commemoration event on Facebook Live at www.facebook.com/Cambodian-Americans. To join zoom meeting, please email to wgc@khmerpeoplenetwork.org for the login info.


PRINT READERSHIP
50,000 Monthly / 600,000 Annually
Plus additional exposure in our online editions at khmerpostusa.com

KhmerPost USA

ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM

2020 PRINTING SCHEDULES
EFFECTIVE FEBRUARY 1, 2020

ADVERTISING RATES AND SIZES
All ads are printed in Full Color

| Ad Size (WxH) | 1 Issue 5% Savings | 3 Months (6 Issues) 7.5% Savings | 6 Months (12 Issues) 10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| Full (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| 1/2 (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| 1/4 (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| 1/8 (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

Your ad is also published in our online editions of the newspaper at khmerpostusa.com




MONTHLY DISTRIBUTION
70+ Locations in Lowell, MA - 7,000 copies
25 Locations in Lynn & Revere, MA - 1,000 copies
25 Locations in Providence & Cranston, RI - 2,000 copies
Additional distribution online

Khmer Post USA
Distribution Locations Include:
Households • Markets • Retail Businesses
Restaurants • Office Buildings • Government Offices
Chamber of Commerce • Buddhist Temple
Laundromats • And Much More

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

Advertising deadlines are 5 business days prior to printing date.

CONTACT INFO
27 Jackson Street • Unit 329 • Lowell, MA 01852
Tel: 978.677.7163 • Fax: 978.677.7092
Email: khmerpostusa@gmail.com
www.khmerpostusa.com

Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau

Follow us @KhmerPostUSA
Follow us @KhmerPostUSA





ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

តមកពីទំព័រទី ០៣

# ក្តៅស៊ីរ៉ាក់ ត្រជាក់ស៊ីជ្រៅ...

អារម្មណ៍ពីសាធារណជននឹងអន្តរជាតិថែមទៀត "តើលោក កឹម សុខា មានបានប្តូរទីសនយោបាយឬ ទេ?"។

លោក សុខា បានត្រឹមតែឆ្លើយយ៉ាងប្រុងប្រយ័ត្នថា"តុលាការមិនអនុញ្ញាត្តិឱ្យលោកធ្វើសកម្មភាពនយោបាយនៅឡើយទេ!"។ មិនធ្វើនយោបាយមែន ប៉ុន្តែលោកសម្តែងការចាប់អារម្មណ៍ ចូលជួយលិយតាមរដ្ឋាភិបាលដើម្បីប្រយុទ្ធជម្ងឺ"កូវីដ១៩" ចំនួន៥ពាន់ដុល្លា, បន្តិចក្រោយមកចូលបុណ្យ៥ពាន់ដុល្លា តាមរដ្ឋាភិបាលដដែលទៅជួយដល់ពលរដ្ឋគ្រាអាសន្នមានទឹកជំនន់ទៀត ។ទាំងនេះជាភារៈកិច្ចរដ្ឋាភិបាលសោះតែលោក កឹម សុខា នៅអាចមានធន់ធានច្រើននៅឡើយ ចេញមុខនៅតាមទ្វារតែមួយដែលបើកចំហរធ្វើឱ្យមានចម្ងល់ទៀតថា"អ្នកគាំទ្រលោកសុខា នៅមានច្រើននៅឡើយមែនឬ?" នៅមានលុយដែលលោក ទៅធ្វើ"បុណ្យកឋិន"នៅតាមខេត្ត ដែល-ជាទីប្រជុំ ពលរដ្ឋជាច្រើនថែមទៀត្យ គឺលោកមិនបានមកធ្វើ ការឃោសនាអ្វីទេ តែមកធ្វើបុណ្យជាប្រពៃណីជាតិតែប៉ុណ្ណោះទេ ។ ធ្វើយ៉ាងនេះ លោក កឹម សុខា បានឱ្យន័យ"មិនធ្វើនយោបាយ"របស់លោកថា "លោកគ្រាន់តែមកធ្វើបុណ្យ ឬក៏ធ្វើអំណោយមនុស្សធមិស្របតាមច្បាប់ដែលរដ្ឋាភិបាលបានអនុញ្ញាត្តិ" តែប៉ុណ្ណោះ។

ទង្វើដដែលនេះ បែរជាឱ្យន័យផ្សេងច្រើនយ៉ាងតែដែលប្រសើនោះ គឺរដ្ឋាភិបាលបានសរសេរលិខិតអរគុណជាលើកដំបូង ដែលកន្លងមកច្រើនជាចម្លើយអវិជ្ជមានធ្វើឱ្យប្រជាពលរដ្ឋព្រួយបារម្មណ៍ទៅវិញ។ តើលិខិតដំបូងមកពីលោក ហ៊ុន សែន បានឱ្យសញ្ញាអ្វីដល់សាធារណជន? ដល់សហគមន៍អន្តរជាតិ? មាន



យោបល់ខ្លះបានចោទប្រកាន់ថា"ហេតុអ្វីក៏យកលុយទៅចូលនឹងរដ្ឋាភិបាល មិនព្រមចែកអំណោយដោយខ្លួនឯងទៅ?" តែលិខិតនេះ លោក ហ៊ុន សែន បានធ្វើឱ្យគេឯងឃើញថាមាន "ការខិតចូលជិតគ្នា" រវាងគណបក្សសត្រូវគ្នាទាំងពីរ។ សំនួរនេះក៏មិនបានទទួលចម្លើយពីលោក កឹម សុខា ដូចគ្នាទៀត្យ លើសពីនេះទៅទៀត ខាងលោក ហ៊ុន សែន ដែលចាំតែចាប់ថ្នាក់ក៏រកចាប់ភស្តុតាងអ្វីមិនបាន្យ ក៏ប៉ុន្តែប្រជាពលរដ្ឋដែលស្រេកឃ្លាននឹងរង់ចាំ"ការប្តូរដៃនៃអំណាច" បានឃើញដៃសប្បុរសជនសិទ្ធិមនុស្សហុចមកជួយពលរដ្ឋគ្រាអាសន្ន ក៏ផ្តើមសង្ស័យថា "អ្នកនយោបាយត្រជាក់រូបនេះ ស៊ីជ្រៅណាស់ទេតើ?", គ្មានបណ្តាញគ្មានរចនាសម្ព័ន្ធគ្មានដៃជើង តែបានបណ្តុះក្តីសង្ឃឹមឡើងវិញ រួចជាស្រេចនៅក្នុងបេះដូងនៃម្ចាស់ឆ្នោតថា "សង្គ្រោះជាតិពិតប្រាកដមិនថា រូបរៀងរបៀបណាទេ នឹងរស់ឡើងវិញ ជាមួយលោក កឹម សុខា"។

**ចុងបញ្ចប់នរណាជាអ្នកឈ្នះ?**

នយោបាយលោក ហ៊ុន សែន ឋិតនៅក្នុងការភិតភ័យនៅឡើយទេ ដោយសារតែពលរដ្ឋ៨0% នៅតែក្រីក្រគ្មានឱកាសនឹងងើបឡើងរួច, ដូច្នេះនៅតែចង់ផ្លាស់ប្តូរអ្នកដឹកនាំដដែលដូចមុន។ រីឯការដុតកំដៅពលរដ្ឋខ្មែរ ដោយការពន្យុះរបស់ សម រង្ស៊ី ឱ្យបះបោរ "ទៅចាប់ ហ៊ុន សែន"នៅពេលខ្លួនឯងគ្មានបំណងពិតនឹងត្រូវគេឯងមើលឃើញបាត់បង់ភាពគាំទ្រ គឺពុំអាចយកឈ្នះអ្វីបានទេ ហើយក៏ជាមនុស្សគ្រោះថ្នាក់ជាទីបំផុត, ពលរដ្ឋជាអ្នកស្រឡាញ់ជាតិ មិនគួរយកអារម្មណ៍ទៅចាយជាមួយ"ជនកុហកគ្មានអៀនខ្មាស់"នោះអី ។

ផ្ទុយទៅវិញ, ដំរាបណាអ្នកនយោបាយខ្មែរចេះគោរពសិទ្ធិសេរីភាពពលរដ្ឋជាម្ចាស់ឆ្នោតប្រុងប្រយ័ត្នពីសុវត្ថិភាពខ្លួនឯង ដើម្បីកាពារប្រជាពលរដ្ឋ, ចេះរក្សាគោលជំហ៊រនយោបាយប្រកបដោយក្តីស្រឡាញ់ ស្មោះពេលនោះ ប្រជាពលរដ្ឋនឹងតបស្នងមកវិញ គេនឹងផ្តល់ជំនឿមកគណបក្ស គេបង្ករជា"ចលនាប្រជាពលរដ្ឋ"គាំទ្រគណបក្សនោះ ដោយគ្មានស្តាយជីវិតនឹងទ្រព្យធន់ នៅពេលគេដឹងឮថា គណបក្សមួយនោះប្រាកដជាស្តាប់ឮសម្លេងទុក្ខព្រួយ នឹងផ្តល់ភាពចំរុងចំរើនដល់ពួកគេ ។លោក កឹម សុខា មកទល់ពេលនេះបានធ្វើសកម្មភាពដឹកនាំគណបក្សសង្គ្រោះជាតិបានល្អប្រសើ ស្គាល់សុខទុក្ខរាស្ត្រ មិនរត់ចោលមិត្រភក្រ្ត មិនរត់ចោលភាពទទួលខុសត្រូវ ទោះជាត្រូវអាជ្ញាធរប្រកាសចាប់ខ្លួនក៏ដោយ - នេះហើយជាភាពត្រជាក់ត្រជុំដែលប្រមូលផ្តុំពលរដ្ឋម្ចាស់ឆ្នោតដឹកដៃគ្នាទៅរកជ័យជំនះបាន។


ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត

URBAN REAL ESTATE

មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន

Residential Leasing Center



ដាញ៉េល តាន

ភ្នាក់ងារអចលនៈទ្រព្យ

Daniel Tan

Real Estate Agent

Cell: 978-902-6354

508 Westford Street • Lowell, MA 01851

(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនស្វូរិន អេជេនស៊ី

KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម

Car • Home • Business



508 Westford Street

Lowell, MA 01851

978-970-2212

kk@kkinsurancema.com



**KhmerPost USA, LLC**

**សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក**



**អគ្គនាយក សុបិន្ទ ពិន**

Soben Pin, Co-Founder|Publisher

Office: 978 677-7163 | Cell: 978-656-8141

Soben@khmerpostusa.com



**និពន្ធនាយកខ្មែរ** Khmer Editorial

និពន្ធនាយក ពិន សំខុន

Roger Samkhon Pin, Co-founder|Editor

978-942-8490 | pinsamkhon@gmail.com

**ផ្សាយពាណិជ្ជកម្ម សុបិន្ទ ពិន**

Advertising Contact

Soben Pin

Cell: 979-656-8141

Soben@khmerpostusa.com

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator

Sokharath Koy | Khmerpostusa@gmail.com

**ច្នៃសោភ័ណ្ឌភាព** Design Artist

Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

**AccuCare**
Home Care Agency
Group Adults Foster Care Program

**ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

**Benefits you will get:**

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតបវារណា

(Tropical Storm)

Continued from page 09

# Cambodia Flood 2020: Death tolls up to 40 people

from outside of the country toward the flood victims, Cambodia Daily—Khmer reports.

The United States is funding $100,000 in humanitarian aid to Cambodia through the U.S. Agency for International Development (USAID) to help the severe flooding, according to a statement released by the U.S. Embassy in Cambodia.

Many hard-hit communities have been cut off from road access. The floods have affected more than 194,000 people, according the U.S. Embassy report. However, Prince Thomico Sisowath said the living conditions of millions of people are affected by this flood, even the reported number is low. Over 250 districts have been flooded and 19 provinces out of 25 provinces are impacted by the flood. More than one half of the country is affected by this flood – a country of 16 millions people. In hard-hit provinces such as Banteay Meanchey and Battambang, each has millions of residents.

At the request Prince Thomico Sisowath, Khmer Post USA has established Cambodia Flood Victims Relief Fund on Sunday October 18, 2020. Every flood victim family will receive $25 that will support them with food suplies for one week to 10 days. Please visit our fundraising campaign at https://gf.me/u/y5dt22 and donate.











ពលរដ្ឋជាច្រើននៅតាមបណ្តាល សហគន៍ទាំងនេះ បានធ្វើតេស្ត ជំងឺ COVID-19 ហើយពួកគេ មានរោគសញ្ញា វិជ្ជមាន ។

# ទីក្រុង LYNN
# និង ទីក្រុង REVERE

## លោកអ្នកមានអំណាចអាចជួយ
## សង្គ្រោះជីវិតមនុស្សបាន



ពាក់ម៉ាស

លាងសំអាតដៃ

រក្សាគម្លាតពីគ្នា

កុំចែករំលែកចំណី អាហារ, ភេសជ្ជៈ ឬក៏ ប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗ

បើលោកអ្នកឈឺ? សូមស្នាក់នៅផ្ទះ

ទៅធ្វើតេស្ត ចំពោះជំងឺ COVID-19

ស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ: Mass.gov/បញ្ឈប់នៅជំងឺ COVID-19